
សូមស្វាគមន៍

ក្លឹបអ្នកកាសែតកម្ពុជា
Club of Cambodian Journalists

ខេមបូឌា ញូស៍
Cambodia News
ក្រុមអ្នកអាជីពផ្នែកសារព័ត៌មាន & សារគមនាគមន៍
Media & Communications Professionals

# វគ្គបណ្តុះបណ្តាល

## ស្តីពី

## តួនាទីនិងការទទួលខុសត្រូវរបស់

# មន្ត្រីព័ត៌មាន/មន្ត្រីអ្នកនាំពាក្យ

## សេចក្តីរាយការណ៍ និពន្ធអត្ថបទ និងទំនាក់ទំនងសាធារណៈ

ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩


មន្ត្រីព័ត៌មាន_អ្នកនាំពាក្យ
រចនាសម្ព័ន្ធ និងសមត្ថកិច្ច

# គួរដឹងពាក្យខាងក្រោមនេះ

អ្នកនាំពាក្យ Spokesperson

មន្ត្រីព័ត៌មាន Media officer

មន្ត្រីទំនាក់ទំនង Communicator

អ្នកសម្របសម្រួល Coordinator

មន្ត្រីទំនាក់ទំនងសាធារណៈ Public Relation Officer

# អ្នកនាំពាក្យ

តួនាទី

មុខងារ

កិច្ចសហការ

រវាងអ្នកនាំពាក្យនិងអ្នកសារព័ត៌មាន

# ការងារអ្នកនាំពាក្យ

## ប្រមូលព័ត៌មាន

## និពន្ធអត្ថបទ (សរុបរាយការណ៍)

## សេចក្តីរាយការណ៍

## និងទំនាក់ទំនងសាធារណៈ

# សារៈសំខាន់ នៃការងារជំនាញ និងការងារទំនាក់ទំនង

- ដើម្បីបំពេញការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈឱ្យបានប្រសើរបំផុតគ្រប់ស្ថាប័ន-អង្គភាពនិងគ្រប់លំដាប់ថ្នាក់រដ្ឋបាលត្រូវតែបង្កើតនូវ ទីតាំងឬការិយាល័យផ្តល់ព័ត៌មាន ដោយត្រូវមានអ្នកនាំពាក្យ ម្នាក់ជាអ្នកទទួលខុសត្រូវ។

# សារៈសំខាន់ នៃការខារជំនាញ និងការខារទំនាក់ទំនង

- ទីតាំងឬការិយាល័យផ្តល់ព័ត៌មានគឺជាផ្នែកមួយនៃរដ្ឋបាល ដែលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ប្រធានហើយ ទីតាំងផ្តល់ព័ត៌មាននេះត្រូវអនុវត្តការងាររបស់ខ្លួនដោយ សេរី និងស្វ័យទទួលខុសត្រូវទាំងការទទួលបានព័ត៌មានពីខាងក្នុង និងពីខាងក្រៅស្ថាប័នឬអង្គភាព។

# សិទ្ធិ និង ភារកិច្ច

- អាជ្ញាធរនិងស្ថាប័នក៏ដូចជាការិយាល័យឬទីតាំងផ្តល់ព័ត៌មានមានកាតព្វកិច្ចប្រឈមមុខនឹងប្រព័ន្ធផ្សព្វផ្សាយអំពីការផ្តល់ដំណឹង ឬព័ត៌មាន។
- ប្រព័ន្ធផ្សព្វផ្សាយគឺធ្វើជាភ្នាក់ងារនាំព័ត៌មានទៅវិញទៅមករវាងអាជ្ញាធរជាតិ និងប្រជាពលរដ្ឋ។ សាធារណៈជនមានសិទ្ធិគ្រប់ពេលវេលាក្នុងការទាមទាររាល់ព័ត៌មានពីអាជ្ញាធរនិងស្ថាប័ន(សិទ្ធិនៃការទទួលបានព័ត៌មាន)

# សិទ្ធិនិងសមត្ថកិច្ចអ្នកនាំពាក្យ

- អ្នកនាំពាក្យមានសិទ្ធិគ្រប់គ្រាន់នៅក្នុងរដ្ឋបាលទាំងមូល នៃស្ថាប័នក្នុងការប្រមូលដំណឹងដែល ពាក់ព័ន្ធទៅនឹង ការងាររបស់ខ្លួន។
- អ្នកនាំពាក្យមានសិទ្ធិគ្រប់គ្រាន់ក្នុងការចូលរួមពិភាក្សាការងារផ្ទៃក្នុងស្ថាប័នឬអង្គភាព និងចូលរួមប្រជុំការងារតាមគណៈកម្មាធិការនានា។

# ការងារអ្នកនាំពាក្យ

- អ្នកនាំពាក្យ មានភារកិច្ចប្រមូលព័ត៌មាន និងជូនព័ត៌មាន ឬ ដំណឹងអំពី ការងាររបស់ស្ថាប័ន ឬអង្គភាព ឱ្យដល់ប្រជាពលរដ្ឋដើម្បីជ្រាបនិងដល់សារព័ត៌មានដើម្បីផ្សព្វផ្សាយឱ្យបានគ្រប់ពេលវេលា ឱ្យបានទូលំទូលាយ និងឱ្យទាន់ហេតុការណ៍។

# ស្រេចើក និង ទាន់ហេតុការ

- អ្នកនាំពាក្យត្រូវតែសកម្ម និងទាន់ហេតុការណ៍ក្នុងការផ្តល់ព័ត៌មានជូនសាធារណៈជន និងប្រព័ន្ធផ្សព្វផ្សាយដោយមានការឯកភាពពីប្រធានស្ថាប័ន និងដោយមធ្យោបាយផ្ទាល់ដែលខ្លួនមាន។

# ទំនាក់ទំនងរវាងអ្នកនាំពាក្យនិងអ្នកសារព័ត៌មាន

- អ្នកនាំពាក្យព័ត៌មានស្ថិតនៅលើផ្នែកម្ខាង ហើយតំណាងស្ថាប័នផ្សព្វផ្សាយស្ថិតនៅលើផ្នែកម្ខាងផ្សេងទៀតប៉ុន្តែគឺមានគោលបំណងរួមគ្នាគឺៈ ” ផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋឱ្យបានត្រឹមត្រូវនិងទៀងទាត់និងទាន់ពេលវេលា ”។

# ទំនាក់ទំនងរវាងអ្នកនាំពាក្យនិងអ្នកសារព័ត៌មាន

- ហេតុដូច្នេះហើយ អ្នកនាំពាក្យត្រូវតែផ្តល់ដំណឹងទៅឱ្យប្រព័ន្ធផ្សព្វផ្សាយ ឱ្យបានលឿន ទូលំទូលាយ និងពិតប្រាកដ។
- ស្ថាប័នផ្សព្វផ្សាយត្រូវផ្តល់ព័ត៌មានបន្តទៅឱ្យសាធារណៈជនដោយ មិនប្រាស់ចាកពីព័ត៌មានដើមដែលបានទទួលឡើយ។

# ទំនាក់ទំនងរវាងអ្នកនាំពាក្យនិងអ្នកសារព័ត៌មាន

អ្នកនាំពាក្យមិនគួររំពឹងថាខ្លួនធ្វើជាមិត្តឬជាសត្រូវនឹងអ្នកសារព័ត៌មាននោះទេ ពីព្រោះអ្នកសារព័ត៌មានគឺជាអ្នកអង្កេតការណ៍ដោយអព្យាក្រឹត្យ អំពីផែនការ និងសកម្មភាពរបស់រដ្ឋបាល-នយោបាយ។ អ្នកសារព័ត៌មាន គឺនៅកណ្តាល រវាងប្រជាពលរដ្ឋនិងស្ថាប័នឬអង្គភាពរដ្ឋនិងឯកជន។

# ភារកិច្ចចំពោះការទាក់ទងជាមួយសារព័ត៌មាន

កិច្ចការរបស់អ្នកនាំពាក្យគឺផ្តល់ឯកសារព័ត៌មានដល់អ្នកសារព័ត៌មានគ្រប់រូបដូច្នេះអ្នកសារព័ត៌មានទាំងនោះអាចបញ្ជូនសារឱ្យសាធារណៈជនបាន។

# លើកទឹកចិត្តអ្នកសារព័ត៌មាន

បណ្ដាញសារព័ត៌មានគឺជាអ្នកប្រមូលផ្ដុំព័ត៌មាននិងជាអ្នកឃ្លាំមើលរវាងអាជ្ញាធរ/គណៈកម្មាធិការនិងប្រជាពលរដ្ឋ ដែលជាអ្នកមានសិទ្ធិផ្ដល់និងទទួលព័ត៌មាននៅគ្រប់ពេលស្ដីអំពីការធ្វើសេចក្ដីសំរេចរបស់អាជ្ញាធរ/គណៈកម្មាធិការទាំងនោះ (សិទ្ធិទទួលព័ត៌មាន)។

# លើកទឹកចិត្តអ្នកសារព័ត៌មាន

- បង្កើនការទំនាក់ទំនងជាមួយអ្នកសារព័ត៌មានគឺមានសារៈសំខាន់ណាស់ ដូចច្នេះការទាក់ទងជាមួយអ្នកសារព័ត៌មានដោយផ្ទាល់គឺត្រូវតែធ្វើឱ្យ បានទៀងទាត់ដោយបញ្ជូនចេញនូវព្រឹត្តប័ត្រសេចក្តីជូនដំណឹងនិងសលាកបត្រព័ត៌មានព្រមទាំងបញ្ជូនលិខិតទៅកាន់ការិយាល័យអ្នកនិពន្ធ។
- សរសើរអ្នកសារព័ត៌មានចំពោះអត្ថបទរបស់គេដែលផ្តោតលើសកម្មភាព របស់ស្ថាប័នហើយលើកទឹកចិត្តពួកគេឱ្យសរសេរបន្ថែមទៀត។

# អ្វីដែលអ្នកនាំពាក្យមិនត្រូវធ្វើ!!!

- ...បដិសេធសំណួររបស់ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ឬ អ្នកសារព័ត៌មាន គេចវេស ឬ ពន្យាពេលវេលា ក្នុងការផ្តល់ចំលើយ។
- ...មិនត្រូវទទួលយក នូវសំភារៈ បរិក្ខា ថវិកា ឬ អត្ថប្រយោជន៍ពិសេស ពីតំណាង ឬពីស្ថាប័នប្រពន្ធ័ផ្សព្វផ្សាយឡើយ។

# សេរីភាពសារព័ត៌មាន

សេរីភាពសារព័ត៌មាន = វិជ្ជាជីវៈ + ការទទួលខុសត្រូវ

រដ្ឋបាលរួមចំណែកធ្វើឱ្យមានសេរីភាពសារព័ត៌មានតាមរយៈដូចខាងក្រោមៈ

១-រៀបចំបង្កើតឱ្យមានរចនាសម្ព័ន្ធការងារព័ត៌មាននៅក្នុងប្រពន្ធ័រដ្ឋបាល

២-បង្កើតឱ្យមានមន្ត្រីព័ត៌មាន/អ្នកនាំពាក្យប្រចាំរដ្ឋបាលនីមួយៗ

៣-ផ្សព្វផ្សាយព័ត៌មានអំពីរដ្ឋបាល និងសេចក្ដីសំរេចចិត្តនានារបស់ស្ថាប័នឬអង្គភាពទៅប្រជាពលរដ្ឋនិងមជ្ឈដ្ឋានសាធារណៈ

# មធ្យោបាយផ្តល់ព័ត៌មានផ្ទាល់សំរាប់សាធារណៈ

អ្នកនាំពាក្យជូនដំណឹងដល់ប្រជាពលរដ្ឋដោយផ្ទាល់តាមរយៈ

- ✓ សន្លឹកឯកសារតូចៗ សាលាកបត្រព័ត៌មាន
- ✓ ផ្ទាកស្លាបិទតាមក្តារខៀន ផ្ទាំងរូបភាព
- ✓ សៀវភៅ ឬ ប័ណ្ណព័ត៌មាន
- ✓ ឧបករណ៍បំពងសំលេង
- ✓ ការជួបប្រជុំជាមួយសាធារណៈជន

# មធ្យោបាយផ្តល់ព័ត៌មានផ្ទាល់សំរាប់សាធារណៈ

- អ៊ិនធើណេត
- ពហុប្រព័ន្ធផ្សព្វផ្សាយ ( Video, CD, DVD, Picture-Shows)
- ការបោះពុម្ពផ្សាយពិសេស
- ព្រឹត្តិការណ៍ (ការតាំងពិព័ណ ទស្សនាបុណ្យទាន...)
- អត្ថបទតាម Web Site

# ផ្តល់ព័ត៌មានប្រយោល (តាមរយៈ Media)

អ្នកនាំពាក្យជូនដំណឹងដល់ប្រជាពលរដ្ឋដោយប្រយោលតាមរយៈប្រព័ន្ធផ្សព្វផ្សាយៈ

- ✓ ទីភ្នាក់ងារសារព័ត៌មាន
- ✓ សារព័ត៌មាន
- ✓ ការសន្ទនាព័ត៌មាន

# ផ្តល់ព័ត៌មានប្រយោល (ត)

- សន្និសិទសារព័ត៌មាន
- ផ្តល់ព័ត៌មានតាមរលកអាកាស (Radio / Telefon)
- ការរៀបចំចាត់ចែងនិងការដឹកនាំកម្មវិធីនៅនឹងកន្លែង
- សម្ភាសន៍
- ពិភាក្សាអំពីរឿងរ៉ាវផ្សេងៗ
- ឆ្លើយតបលិខិតមិត្តអ្នកអាន

# សំភារៈបំរើឲ្យការិយាល័យព័ត៌មាន

- កុំព្យូទ័រភ្ជាប់ប្រព័ន្ធអ៊ីនធឺរណិត-អ៊ីមែលនិងបណ្តាញកុំព្យូទ័រផ្ទៃក្នុង
- ម៉ាស៊ីនព្រីនធ័រពណ៌ធម្មជាតិ
- ម៉ាស៊ីនស្កែនណឺរ
- ម៉ាស៊ីនថតចំលង
- ម៉ាស៊ីនហ្វាក់
- ទូរសព្ទ័ខ្សែ និង ទូរសព្ទ័ដៃ
- ម៉ាស៊ីនថតសំលេង ឌីជីថល
- កាមេរ៉ាថតរូប ឌីជីថល
- កាមេរ៉ាថតវីដេអូ ឌីជីថល


សូមអរគុណ